# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៨៧.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់
## គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនា "ភូមិមួយផលិតផលមួយ"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិជំរុញចលនា "ភូមិមួយផលិតផលមួយ" ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ/

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៧/៣៨៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា១និងមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ សរសេរជាអក្សរកាត់ថា "**គ.ជ.ភ១.ផ១.**"។

## ជំពូកទី២

## តួនាទីនិងភារកិច្ច

**មាត្រា២ .-**

**គ.ជ.ភ១.ផ១.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សា រៀបចំ និងអនុវត្តគោលនយោបាយជាតិនិងយុទ្ធសាស្ត្រ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ដើម្បីជំរុញការផលិត ការកែច្នៃផលិតផលកសិកម្ម និងសិប្បកម្មមូលដ្ឋានតាមបែបប្រពៃណីនិងទំនើបឲ្យសមស្របទៅនឹងតម្រូវការនៅទីផ្សារក្នុងស្រុកនិងក្រៅស្រុក និងបម្រើដល់វិស័យទេសចរណ៍ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជនបទ
- តាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយជាតិនិងយុទ្ធសាស្ត្រ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ក្រុមហ៊ុនឯកជន អង្គការជាតិ អន្តរជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលនិងផ្តល់ការលើកទឹកចិត្តដល់ផលិតករ កសិករ សេវាករ សិប្បករ សមាគម និងសហគមន៍ ដើម្បីជំរុញឲ្យមានចលនាភូមិមួយផលិតផលមួយនៅទូទាំងប្រទេស
- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានា ដែលកំពុងអនុវត្តចលនាភូមិមួយផលិតផលមួយ ឬចលនាស្រដៀងគ្នា ដើម្បីពង្រឹងពង្រីកចលនាភូមិមួយផលិតផលមួយ នៅកម្ពុជាឲ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព
- សហការនិងសម្របសម្រួលជាមួយវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនានា ទាំងស្ថាប័នរដ្ឋ និងឯកជន ដើម្បីផ្តល់បទពិសោធ និងទំនើបភាវូបនីយកម្មដល់ផលិតករ សិប្បករ កសិករ សេវាករ សមាគម និងសហគមន៍
- តាមដាននិងវាយតម្លៃការងារអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ
- ពិនិត្យនិងអនុម័តរបាយការណ៍ជូននាយករដ្ឋមន្ត្រី អំពីសកម្មភាពរបស់ខ្លួនរៀងរាល់ឆមាសនិងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។/

# ជំពូកទី៣
## ការប្រព្រឹត្តទៅរបស់ គ.ជ.ភ១.ផ១.

**មាត្រា៣ ៖**

**គ.ជ.ភ១.ផ១.** មានសិទ្ធិរៀបចំគណៈកម្មការ ឬក្រុមការងារបច្ចេកទេសផ្សេងៗទៀត តាមតម្រូវការចាំបាច់។ គណៈកម្មការឬក្រុមការងារបច្ចេកទេសនេះត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ភ១.ផ១.**។

**មាត្រា៤ ៖**

**គ.ជ.ភ១.ផ១.** ត្រូវធ្វើការប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំ។ ក្នុងករណីចាំបាច់ ប្រធាន **គ.ជ.ភ១.ផ១.** អាចកោះប្រជុំជាវិសាមញ្ញបាន។

សមាជិក **គ.ជ.ភ១.ផ១.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំការប្រជុំ។

ប្រធាន **គ.ជ.ភ១.ផ១.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អ្នកឯកទេសដែលពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងអង្គភាពឯកជន ចូលរួមផ្តល់យោបល់ក្នុងអង្គប្រជុំតាមការចាំបាច់។

**មាត្រា៥ ៖**

**គ.ជ.ភ១.ផ១.** មានសិទ្ធិចេញសេចក្តីណែនាំផ្សេងៗទៅតាមតម្រូវការចាំបាច់ ដើម្បីសម្រួលដល់ការសម្របសម្រួល សហការ គ្រប់គ្រង និងតាមដាន វាយតម្លៃ ការអនុវត្តគោលនយោបាយជាតិនិងយុទ្ធសាស្ត្រស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ។

**មាត្រា៦ ៖**

**គ.ជ.ភ១.ផ១.** អាចស្នើតែងតាំងទីប្រឹក្សាអម អ្នកជំនាញការ ឬអ្នកស្ម័គ្រចិត្តខ្មែរ ឬបរទេស ដើម្បីជួយសិក្សានិងផ្តល់យោបល់លើការងារជំនាញនីមួយៗ។

**មាត្រា៧ ៖**

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ ដោយប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់នៅក្នុងក្រសួង ស្ថាប័ន ហើយតួនាទី ភារកិច្ចរបស់ក្រុមការងារត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័ននោះ ដោយផ្អែកតាមសេចក្តីណែនាំរបស់ **គ.ជ.ភ១.ផ១.**។

**មាត្រា៨ ៖**

រាជធានី ខេត្តត្រូវបង្កើតគណៈកម្មាធិការរាជធានី ខេត្តជំរុញចលនាភូមិមួយផលិតផលមួយ ដើម្បីបំពេញបេសកកម្មនិងមុខងារដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលដែនដី ក្នុងការលើកស្ទួយនិងជំរុញចលនាភូមិមួយផលិតផលមួយ។ សមាសភាពគណៈកម្មាធិការរាជធានី ខេត្តជំរុញចលនាភូមិមួយផលិតផលមួយ និងតួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយផ្អែកតាមសេចក្តីណែនាំរបស់ **គ.ជ.ភ១.ផ១.**។

**មាត្រា៩ ៖**

ត្រូវបង្កើតសហគមន៍ ឬសមាគមទ្រទ្រង់ចលនាភូមិមួយផលិតផលមួយដើម្បីលើកស្ទួយនិងជំរុញចលនាភូមិមួយផលិតផលមួយ នៅគ្រប់កម្រិត តាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១០ ._**

**គ.ជ.ត១.ផ១.** ត្រូវមានអគ្គលេខាធិការដ្ឋានមួយ ដែលហៅកាត់ថា "**អគ្គលេខាធិការដ្ឋាន ត១.ផ១.**" ជាសេនាធិការ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ ដែលមានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី។

## ជំពូកទី៤

## រចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ត១.ផ១.

**មាត្រា១១ ._**

**អគ្គលេខាធិការដ្ឋាន ត១.ផ១.** មានតួនាទីនិងភារកិច្ចដូចតទៅៈ

- ទទួលបន្ទុកចាត់ការទូទៅគ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពនិងការងារប្រចាំថ្ងៃរបស់ **គ.ជ.ត១.ផ១.**
- ដឹកនាំ សម្របសម្រួលរៀបចំសេចក្តីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ សកម្មភាពនិងឯកសារគតិយុត្តនានាក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ ដាក់ជូន **គ.ជ.ត១.ផ១.** ពិនិត្យនិងសម្រេច
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ សកម្មភាពចលនាភូមិមួយផលិតផលមួយ ដោយលើកយោបល់និងដំណោះស្រាយនានា ជូន **គ.ជ.ត១.ផ១.** សំដៅជំរុញប្រសិទ្ធភាពនៃការងារ
- សម្របសម្រួលនិងសហការជាមួយនឹងក្រសួង ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ និងវិស័យឯកជន ក្នុងការជំរុញសកម្មភាពចលនាភូមិមួយផលិតផលមួយ
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍលើផលិតផលនានា ក្នុងក្របខណ្ឌភូមិមួយផលិតផលមួយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារទាំងក្នុងស្រុកនិងក្រៅស្រុក
- ជំរុញនិងលើកទឹកចិត្តគាំទ្រដល់សមាគម សហគមន៍ កសិករ សិប្បករ សេវាករ និងផលិតករផ្សេងៗទៀតក្នុងការផលិតការកែច្នៃផលិតផលឲ្យមានគុណភាពនិងតម្លៃបន្ថែម
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធស្វែងរកទីផ្សារទាំងក្នុងស្រុកនិងក្រៅស្រុក ដើម្បីជួយដល់សមាគម សហគមន៍ កសិករ សិប្បករ សេវាករ និងផលិតករផ្សេងៗទៀតនៅក្នុងស្រុកដើម្បីលក់ផលិតផលរបស់ខ្លួន
- សម្របសម្រួលនិងបណ្តុះបណ្តាលជំនាញនានាដល់សមាគម សហគមន៍ កសិករ សិប្បករ សេវាករ និងផលិតករផ្សេងៗទៀតលើការរៀបចំផែនការអាជីវកម្ម និងកិច្ចដំណើរការអាជីវកម្មមួយប្រកបដោយគុណភាពផលិតខ្ពស់ មានការវេចខ្ចប់បានល្អ មានបរិមាណសមស្រប និងតម្លៃសមស្រប សម្រាប់ទីផ្សារ
- ស្វែងរកជំនួយនិងកិច្ចសហការនានាទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ពីបណ្តាស្ថាប័ន ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ ស្ថាប័នហិរញ្ញវត្ថុជាតិនិងអន្តរជាតិ និងវិស័យឯកជន ក្នុងការជួយគាំទ្រសកម្មភាពជំរុញចលនាភូមិមួយផលិតផលមួយ
- សម្របសម្រួលក្នុងការដឹកនាំនិងរៀបចំការចែករំលែកបទពិសោធ ពីសមាគមឬសហគមន៍មួយទៅសមាគមឬសហគមន៍មួយទៀតក្នុងរាជធានី ខេត្តទូទាំងប្រទេស/.

- ផ្សព្វផ្សាយគោលនយោបាយ ផលិតផល និងសកម្មភាពនៃចលនាភូមិមួយផលិតផលមួយតាមគ្រប់មធ្យោបាយនៃបណ្តាញព័ត៌មាន
- ជួយសម្របសម្រួលនិងរៀបចំចងក្រងបណ្តាញសមាគមឬសហគមន៍អ្នកផលិតនៅតាមបណ្តាខេត្ត និងរាជធានីទូទាំងប្រទេស
- ប្រជុំបូកសរុបលទ្ធផលការងាររបស់ **អគ្គលេខាធិការដ្ឋាន គ១.ផ១.** និងរៀបចំរបាយការណ៍រៀងរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំជូន **គ.ជ.គ១.ផ១.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាន **គ.ជ.គ១.ផ១.** ប្រគល់ជូន។

**មាត្រា១២ ._**

**អគ្គលេខាធិការដ្ឋាន គ១.ផ១.** ត្រូវដឹកនាំគ្រប់គ្រងផ្ទាល់ដោយអគ្គលេខាធិការមួយរូប ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ អមដោយអគ្គលេខាធិការរងមួយចំនួនអនុលោមតាមបទប្បញ្ញត្តិជាធរមាន ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

អគ្គលេខាធិការរងបំពេញភារកិច្ចតាមសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.គ១.ផ១.** តាមសំណើរបស់អគ្គលេខាធិការ។

**មាត្រា១៣ ._**

**អគ្គលេខាធិការដ្ឋាន គ១.ផ១.** ត្រូវរៀបចំការប្រជុំយ៉ាងតិច១(មួយ)ដងក្នុងមួយខែ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការឲ្យមានភាពរលូន។

**មាត្រា១៤ ._**

**អគ្គលេខាធិការដ្ឋាន គ១.ផ១.** មានមន្ត្រីបម្រើការងារជាមន្ត្រីក្របខណ្ឌមុខងារសាធារណៈនិងមន្ត្រីជាប់កិច្ចសន្យា។

**មាត្រា១៥ ._**

**អគ្គលេខាធិការដ្ឋាន គ១.ផ១.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ អ្នកជំនាញការជាតិ អន្តរជាតិ និងវិស័យឯកជនចូលរួមពិភាក្សាលើបញ្ហានានាដែលពាក់ព័ន្ធនឹងការងារជំរុញចលនាភូមិមួយផលិតផលមួយ។

**មាត្រា១៦ ._**

**អគ្គលេខាធិការដ្ឋាន គ១.ផ១.** មាននាយកដ្ឋានចំណុះចំនួន៤(បួន)គឺៈ

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍
- នាយកដ្ឋានទីផ្សារនិងស្តង់ដា
- នាយកដ្ឋានទំនាក់ទំនងសាធារណៈ

អង្គការលេខរបស់ **អគ្គលេខាធិការដ្ឋាន គ១.ផ១.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា១៧ ._**

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានមួយចំនួនអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

នាយកដ្ឋាននីមួយៗមានការិយាល័យជំនាញមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធាន **គ.ជ.ភ១.ផ១.**។

**មាត្រា១៨ ._**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ទទួលខុសត្រូវលើការងាររដ្ឋបាលទូទៅនិងហិរញ្ញវត្ថុ ជូនគ្រប់អង្គភាពនៅក្រោមឱវាទ **អគ្គលេខាធិការដ្ឋាន ភ១.ផ១.**
- គ្រប់គ្រងឯកសារក្របខណ្ឌមន្ត្រីរាជការបុគ្គលិក និងសម្របសម្រួលលើកិច្ចការពាក់ព័ន្ធផ្នែកអភិវឌ្ឍធនធានមនុស្សនៅគ្រប់អង្គភាពនៃអគ្គលេខាធិការដ្ឋាន
- ទទួលបន្ទុកចាត់ចែងរៀបចំការងាររដ្ឋបាលនានាពាក់ព័ន្ធនឹងកិច្ចប្រជុំ សិក្ខាសាលានិងទស្សនកិច្ចផ្សេងៗ
- រៀបចំគម្រោងថវិកាសម្ភារៈ និងមធ្យោបាយនានាប្រចាំឆ្នាំរបស់ **គ.ជ.ភ១.ផ១.**
- គ្រប់គ្រងនិងបែងចែកសម្ភារៈបរិក្ខារជូនគ្រប់អង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន
- គ្រប់គ្រង ថែទាំ ផ្គត់ផ្គង់ និងធ្វើបញ្ជីសារពើភណ្ឌនៃចលនទ្រព្យនិងអចលនទ្រព្យរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រងនិងប្រតិបត្តិថវិកាឲ្យបានត្រឹមត្រូវទៅតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារពាក់ព័ន្ធប្រាក់បៀវត្ស ការស្នើប្រាក់ឧបត្ថម្ភ បែបបទស្នើសុំដំឡើងឋានន្តរស័ក្តិ និងគ្រឿងឥស្សរិយយសផ្សេងៗជូនមន្ត្រីរាជការនិងបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន **ភ១.ផ១.**
- ធ្វើកំណត់ហេតុប្រជុំរបស់ **គ.ជ.ភ១.ផ១.** និងកិច្ចប្រជុំអគ្គលេខាធិការដ្ឋាន **ភ១.ផ១.**
- រៀបចំរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាសនិងប្រចាំឆ្នាំ ស្តីពីសកម្មភាពនិងលទ្ធផលការងាររបស់ **អគ្គលេខាធិការដ្ឋាន ភ១.ផ១.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា១៩ ._**

នាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ប្រមូលផ្តុំនិងចងក្រងអ្នកជំនាញតាមក្រសួង ស្ថាប័ន សហគមន៍ អង្គការជាតិនិងអន្តរជាតិពាក់ព័ន្ធដើម្បីចូលរួមក្នុងចលនាភូមិមួយផលិតផលមួយ
- សិក្សាស្រាវជ្រាវនូវទ្រឹស្តី បទពិសោធ ឧបករណ៍សម្ភារៈ ឬបច្ចេកទេសទំនើបៗសម្រាប់ជំរុញការងារភូមិមួយផលិតផលមួយ
- ប្រមូលផ្តុំទិន្នន័យផលិតផលតាមប្រភេទពីបណ្តារាជធានី ខេត្ត ដើម្បីកសាងផែនទីផលិតផលភូមិមួយផលិតផលមួយ
- កំណត់លក្ខណសម្បត្តិផលិតផល ទីកន្លែង និងជ្រើសរើសផលិតផលដែលមានសក្តានុពលសម្រាប់ជំរុញចលនាភូមិមួយផលិតផលមួយ
- រៀបចំឯកសារស្រាវជ្រាវនិងអភិវឌ្ឍផលិតផលភូមិមួយផលិតផលមួយ ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយ

- សម្របសម្រួលនិងសហការជាមួយនឹងក្រសួង ស្ថាប័នជំនាញដើម្បីចងក្រង ពង្រឹង និងពង្រីកសមាគម ឬសហគមន៍ផលិតទាំងឡាយទៅតាមជំនាញ រួមមានវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម
- ជ្រើសរើសសមាគម សហគមន៍ ឬភូមិគំរូ នៃភូមិមួយផលិតផលមួយតាមបណ្ដារាជធានី ខេត្ត ដើម្បីជំរុញចលនាភូមិមួយផលិតផលមួយ
- សហការជាមួយដៃគូជាតិនិងអន្តរជាតិ សម្រាប់ជួយជាបច្ចេកទេសនិងហិរញ្ញវត្ថុដល់ដំណើរការអនុវត្តក្នុងការអភិវឌ្ឍធនធានមនុស្សលើការស្រាវជ្រាវនិងអភិវឌ្ឍ
- រៀបចំផែនការសកម្មភាពបណ្ដុះបណ្ដាលធនធានមនុស្ស លើការស្រាវជ្រាវនិងអភិវឌ្ឍរយៈពេលខ្លី មធ្យម និងវែង
- រៀបចំកម្មវិធីផ្លាស់ប្ដូរបទពិសោធ ទស្សនកិច្ចសិក្សា ដល់សហគ្រិន យុវជន សហគមន៍ និងសមាគមភូមិមួយផលិតផលមួយ
- សម្របសម្រួលនិងសហការជាមួយនាយកដ្ឋាននានា ក្នុងការអនុវត្តចលនាភូមិមួយផលិតផលមួយនៅតាមរាជធានី ខេត្តទូទាំងប្រទេស
- រៀបចំរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា២០.-**

នាយកដ្ឋានទីផ្សារនិងស្តង់ដា មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រៀបចំគម្រោងអភិវឌ្ឍទីផ្សារនិងស្តង់ដានៃផលិតផលភូមិមួយផលិតផលមួយ
- វិភាគសិក្សាអំពីតម្រូវការទីផ្សារផលិតផលភូមិមួយផលិតផលមួយ
- សហការជាមួយនឹងក្រសួងពាណិជ្ជកម្ម ដើម្បីរកទីផ្សារលក់និងទីកន្លែងតាំងបង្ហាញផលិតផលភូមិមួយផលិតផលមួយ ទាំងក្នុងនិងក្រៅប្រទេស និងការរៀបចំព្រឹត្តិការណ៍ផ្សេងៗនៅតាមរាជធានីនិងបណ្ដាខេត្តនានា
- សហការជាមួយនឹងស្ថាប័នជំនាញក្រសួង អង្គការ ស្ថាប័នពាក់ព័ន្ធ រួមទាំងនាយកដ្ឋាននានាក្រោមឱវាទ **អគ្គលេខាធិការដ្ឋាន គ១.ផ១**. ដើម្បីអភិវឌ្ឍផលិតផលថ្មី ឬកែលម្អផលិតផលដែលមានស្រាប់ឲ្យស្របតាមឱកាសនិងតម្រូវការទីផ្សារ
- សម្របសម្រួលនិងសហការជាមួយនឹងក្រសួង ស្ថាប័នជំនាញដើម្បីរៀបចំបង្កើតនិងចងក្រងស្តង់ដាផលិតផលភូមិមួយផលិតផលមួយ
- សហការជាមួយដៃគូជាតិនិងអន្តរជាតិ សម្រាប់ជួយជាបច្ចេកទេសនិងហិរញ្ញវត្ថុដល់ដំណើរការរកទីផ្សារ
- រៀបចំឯកសារទីផ្សារនិងស្តង់ដាផលិតផលភូមិមួយផលិតផលមួយ ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយ
- រៀបចំការប្រកួតប្រជែងផលិតផលឈានមុខនៃផលិតផលភូមិមួយផលិតផលមួយ
- សិក្សារកទីតាំងសម្រាប់រៀបចំមជ្ឈមណ្ឌល ស្តង់ ផ្សាររាត្រី ឬផ្សារភូមិមួយផលិតផលមួយ សម្រាប់ដាក់តាំងនិងលក់ផលិតផលខ្មែរ
- រៀបចំបណ្ដាញទីផ្សារភូមិមួយផលិតផលមួយ នៅតាមកន្លែងផ្សារបោះដុំ ផ្សារទំនើប សណ្ឋាគារ ទីចំណតរថយន្តក្រុង ស្ថានីយប្រេងឥន្ធនៈ និងនៅតាមភោជនីយដ្ឋាននានា។

- រៀបចំវគ្គបណ្តុះបណ្តាលឬសិក្ខាសាលាបម្រើឲ្យផ្នែកទីផ្សារ
- រៀបចំរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

**មាត្រា២១ .-**

នាយកដ្ឋានទំនាក់ទំនងសាធារណៈ មានតួនាទីនិងភារកិច្ចដូចខាងក្រោមនេះ៖

- រៀបចំផែនការយុទ្ធសាស្ត្រការផ្សព្វផ្សាយនិងយុទ្ធនាការលើកកម្ពស់ផលិតផលភូមិមួយផលិតផលមួយ
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ស្ថានទូតបរទេសនៅកម្ពុជា ស្ថានទូតកម្ពុជានៅបរទេស ស្ថានកុងស៊ុល ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិលើកគម្រោងចលនាភូមិមួយផលិតផលមួយ
- ផ្សព្វផ្សាយទស្សនាទាន គោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពនៃចលនាភូមិមួយផលិតផលមួយដល់ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាជននៅមូលដ្ឋានដើម្បីទទួលបានការគាំទ្រ និងការចូលរួមអនុវត្តឲ្យសម្រេចបានជោគជ័យ
- រៀបចំគម្រោងផ្សព្វផ្សាយអំពីចលនាភូមិមួយផលិតផលមួយ តាមរយៈគេហទំព័រ វិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងមធ្យោបាយផ្សេងៗទៀត
- រៀបចំយុទ្ធសាស្ត្រព័ត៌មាន អប់រំ និងទំនាក់ទំនង សម្រាប់ការផ្សព្វផ្សាយព័ត៌មាន និងការអប់រំដល់ការគាំទ្រ និងលើកកម្ពស់សកម្មភាពជំរុញចលនាភូមិមួយផលិតផលមួយ
- រៀបចំរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ជូន។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា២២ .-**

ការចំណាយសម្រាប់ដំណើរការរបស់ **គ.ជ.ភ១.ផ១.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**គ.ជ.ភ១.ផ១.** មានសិទ្ធិកៀគរថវិកាពីប្រភពផ្សេង ដើម្បីបង្កើតមូលនិធិចលនាភូមិមួយផលិតផលមួយ និងមានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនិតិវិធីច្បាប់ជាធរមាននូវមូលនិធិទាំងនោះដែលបានមកពីប្រភពផ្សេងៗសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## រូបសញ្ញានិងត្រា

**មាត្រា២៣ .-**

**គ.ជ.ភ១.ផ១.** មានរូបសញ្ញាផ្ទាល់របស់ខ្លួននិងមានសិទ្ធិប្រើត្រារបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៤ .-**

អនុក្រឹត្យលេខ៤៣៦ អនក្រ.តត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ **គ.ជ.ភ១.ផ១.** និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ខែ តុលា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការនិងជារដ្ឋមន្ត្រីស្តីទី**

**ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ប៊ិន ឈិន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ